មហាបុរស កែម ឡី

សេរីការ

សូមចូលរួមរំលែកទុក្ខដល់គ្រួសារសពមហាបុរស

ឃាតកម្មលើរូបមហាបុរស កែម ឡី ជា សន្ទស្សន៍[1]មួយបញ្ជាក់ឲ្យឃើញថា របបដឹកនាំនៅស្រុកខ្មែរបច្ចុប្បន្ន ជា សេណីនៃឃាតករ[2] ឈ្មោះថា « បាតដៃទី៣ » បំរើប្រយោជន៍ឃួន ស៊ី ផលកម្រៃពីអំពើពុករលួយ ហ៊ាន សម្លាប់ កូនខ្មែរ ដែលជា អ្នកស្នេហាជាតិ ជាស្វាមី និង ជាបិតា ដើម្បី ការពារ អំណាចផ្តាច់ការ និង អត្ថប្រយោជន៍ក្រុមគ្រួសារ។ ឃាតកម្មនេះ ជាអំពើប្រឆាំងនឹងមនុស្សជាតិ និងជា អំពើក្បត់ជាតិ ជាក់ស្តែងដែលលោក ហ៊ុន សែន តាំងខ្លួនជានាយករដ្ឋមន្ត្រី ការពារសន្តិភាពជាតិត្រូវទទួលខុសត្រូវទាំងស្រុង។ ការចាប់ខ្លួនឃាតករបានភ្លាមៗ គ្រាន់តែជាក្រឡេចមួយរបស់អ្នកដឹកនាំសព្វថ្ងៃ ចង់យករួចខ្លួន ថាខ្លួននៅ ក្រៅរឿងឃាតកម្ម ដ៏អប្រិយនេះ តែល្បិចខូចនេះ វាពុំអាចនរណាមួយ គេអាចជឿបាននោះឡើយ ព្រោះពួកអ្នកដឹកនាំសព្វថ្ងៃ គាត់មានចរិតជាឃាតករ ត្បិតអំពើឃាតកម្ម វាជារបរសំរាប់ចិញ្ចឹមជីវិតអំណាចរបស់ពួកគាត់។

---

[1] សន្ទស្សន៍ ; signe។
[2] សេណីនៃឃាតករ ; club des assassins។